# កញ្ញា និត វ៉ាន់យូ

*“អ្នកស្រឡាញ់ភេទដូចគ្នា គឺជាធនធានមនុស្ស និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍ សង្គម។ ដូច្នេះ អ្នកស្រឡាញ់ភេទដូចគ្នា ក៏ជាផ្នែកមួយដ៏សំខាន់នៃសង្គមនេះដែរ។”*



កញ្ញា និត វ៉ាន់យូ មានអាយុ ៣១ឆ្នាំ បច្ចុប្បន្នមានមុខរបរជាអ្នកសម្អាងការ។ កញ្ញាបានក្លាយជាសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នានៅខេត្តសៀមរាបចាប់តាំងពីឆ្នាំ២០០៦ មកម្ល៉េះ។ កញ្ញាបានដឹងពីនិន្នាការភេទរបស់ខ្លួននៅអាយុ ១២ ឆ្នាំ ហើយចាប់តាំងពីពេលនោះមកវាបានក្លាយជាការប្រឈមសម្រាប់កញ្ញា ដោយសារតែកញ្ញាត្រូវបានគេរើសអើង និងផាត់ចេញពីសំណាក់គ្រួសារ និងសង្គម។

ដោយសារកញ្ញាផ្ទាល់ជាជនរងគ្រោះ និងបានមើលឃើញបញ្ហាជាច្រើនដែលអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះដូចជា ការតស៊ូមតិនៅមានកម្រិត ការរើសអើងពីគ្រួសារ និងសង្គម ដូច្នេះកញ្ញាតែងតែលើកឡើងពីបញ្ហាប្រឈមរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅពេលចូលរួមកម្មវិធី ឬវគ្គបណ្តុះបណ្តាលរបស់អង្គការមិនមែនរដ្ឋាភិបាល។ លើសពីនេះទៀត កញ្ញាបានចងក្រងបណ្តាញនៅក្នុងសហគមន៍របស់ខ្លួន ហើយបច្ចុប្បន្ននេះបណ្តាញមានសមាជិកចំនួន ៣៣ នាក់ហើយ។ កញ្ញាបានធ្វើការជាមួយសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសុខភាព និងការតស៊ូមតិ ដើម្បីទាមទារសិទ្ធិផ្សេងៗក្រៅពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាទៀតផងដូចជាសិទ្ធិរបស់អ្នករស់នៅជាមួយមេរោគអេដស៍ សិទ្ធិមនុស្សចាស់ជរា សិទ្ធិកុមារ សិទ្ធិបុរស និងសិទ្ធិស្ត្រី។ គួរឱ្យចាប់អារម្មណ៍ផងដែរនោះ នៅក្នុងឆ្នាំ២០១៦ កញ្ញា បានរៀបចំ *“វេទិកាតស៊ូមតិអ្នកស្រឡាញ់ភេទដូចគ្នា”* នៅស្រុកបន្ទាយស្រី ក្នុងគោលបំណងដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងខេត្តសៀមរាប ដែលមានចៅហ្វាយស្រុកចូលរួមដើម្បីលើកទឹកចិត្ត និងបង្ហាញការគាំទ្រក្នុងការលុបបំបាត់ការរើសអើង និងការប្រើអំពើហិង្សាប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសហគមន៍ក្នុងគោលបំណងដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន។

ក្នុងនាមជាសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា គឺមានភាពលំបាកពីព្រោះសិទ្ធិ និងសេរីភាពរបស់កញ្ញាត្រូវបានរឹតត្បិតពីសំណាក់គ្រួសារ និងសង្គម។ ក្រៅពីនេះ កញ្ញាត្រូវបានសហគមន៍មើលងាយទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័ររបស់កញ្ញាទៀតផង។ អ្វីដែលសំខាន់បំផុតនោះគឺអាជ្ញាធរមូលដ្ឋានមិនទទួលស្វាគមន៍ការតស៊ូមតិរបស់កញ្ញា ដើម្បីទាមទារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសហគមន៍ឡើយ។

កញ្ញាយល់ថាសមភាពយេនឌ័រ គឺជាភាពស្មើភាពគ្នានៃយេនឌ័រទាំងអស់ ដោយមិនគិតពីភេទ យេនឌ័រ ពណ៌សម្បុរ ជំនឿសាសនា ស្ថានភាពសង្គម និងទ្រព្យសម្បត្តិឡើយ។ កញ្ញាបានកត់សម្គាល់ឃើញថា ច្បាប់

ពុំទាន់បានរាប់បញ្ចូលសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅឡើយទេ។ ទន្ទឹមនឹងនេះ កញ្ញាជឿជាក់ថា អត្ថិភាពនៃអំពើហិង្សាប្រឆាំងនឹងភេទអាចបង្កឱ្យមានផលអវិជ្ជមានដល់សង្គមជាច្រើនដូចជា ការកើនឡើងនៃអត្រាជនអន្តោប្រវេសន៍ ការកើនឡើងនៃអត្រាធ្វើអត្តឃាត និងការធ្លាក់ចុះនៃធនធានមនុស្សរបស់ប្រទេសផងដែរ។ ហេតុដូច្នេះហើយបានជាកញ្ញាមានគំនិតយ៉ាងវិជ្ជមាន និងតស៊ូដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា ជួយលើកកម្ពស់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា កាត់បន្ថយការរើសអើង និងផ្ទេរចំណេះដឹងតាមរយៈការធ្វើសកម្មភាពតស៊ូមតិ៕

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

CC BY NC SA

ខែធ្នូ ឆ្នាំ២០១៩